ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០៧០......សហវ.ប្រក

ក្រសួងមហាផ្ទៃ

# ប្រកាសអន្តរក្រសួង

## ស្តីពី

## នីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជី នៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ

## សម្រេច

### ប្រការ១._

ប្រកាសនេះមានគោលបំណងកំណត់បែបបទ និងនីតិវិធីសម្រាប់ពិនិត្យសម្រេចលើសំណើនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) និងគម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ព.គ.ល.គ.) ដែលបានចុះបញ្ជីនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (អ.គ.វ.រ.ខ.)។

### ប្រការ២._

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ អ.គ.វ.រ.ខ. ក្នុងការពិនិត្យ និងសម្រេចលើការផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ចំពោះការនាំចូល និងការប្រើប្រាស់នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់ គ.ល.គ. និង គ.ព.គ.ល.គ. ដែលបានចុះបញ្ជីនៅ អ.គ.វ.រ.ខ.។

### ប្រការ៣._

ការស្នើសុំនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១- អ្នកដាក់ពាក្យស្នើសុំត្រូវតែជាបុគ្គលដែលអនុវត្តគម្រោងវិនិយោគ ឬអ្នកតំណាងដែលមានសិទ្ធិ។

២- អ្នកដាក់ពាក្យស្នើសុំត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរនៅ អ.គ.វ.រ.ខ.។

៣- អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញព័ត៌មានចាំបាច់តាមទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី១នៃប្រកាសអន្តរក្រសួងនេះ។

ការស្នើសុំនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ដែលបានបំពេញត្រឹមត្រូវតាមពាក្យស្នើសុំ និងទម្រង់ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ត្រូវចុះហត្ថលេខាដោយបុគ្គលដែលត្រូវអនុវត្តគម្រោងវិនិយោគ ឬដោយអ្នកតំណាងដែលមានសិទ្ធិ។ ក្នុងករណីពាក្យស្នើសុំត្រូវបានចុះហត្ថលេខាដោយអ្នកតំណាងដែលមានសិទ្ធិ អ្នកតំណាងនោះត្រូវប្រគល់លិខិតផ្ទេរសិទ្ធិដែលបញ្ជាក់អំពីសិទ្ធិជាអ្នកតំណាង និងឯកសារគាំទ្រដែលបញ្ជាក់ពីវិសាលភាពនៃសិទ្ធិសម្រេច។

ការដាក់ពាក្យស្នើសុំ និងការទទួលលិខិតអនុញ្ញាតនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋត្រូវអនុវត្តតាមនីតិវិធីនៃការផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ឬអាចធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។

កម្រៃសេវានៃការស្នើសុំការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ត្រូវបន្តអនុវត្តតាមប្រកាសរួមលេខ ៩៨១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រហូតដល់មានការកំណត់តម្លៃសេវាសាធារណៈថ្មីមកជំនួស ដែលរៀបចំឡើងដោយប្រកាសអន្តរក្រសួងស្តីពីការកំណត់តម្លៃសេវាសាធារណៈរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

## ប្រការ៤._

អ.គ.វ. វ.ខ. ត្រូវពិនិត្យសម្រេចសំណើសុំនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋតាមរយៈយន្តការអន្តរស្ថាប័ន ក្នុងរយៈពេលមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យស្នើសុំ។

លិខិតអនុញ្ញាតឱ្យនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ត្រូវបានផ្តល់ជូនតាមទម្រង់ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃប្រកាសអន្តរក្រសួងនេះ។

អ.គ.វ.វ.ខ. មានសិទ្ធិពន្យារពេល ឬមិនផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋជូនអ្នកដាក់ពាក្យសុំ ដោយត្រូវជូនដំណឹង និងបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ក្នុងករណីចាំបាច់តម្រូវឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវ ឬបំពេញបន្ថែម។

## ប្រការ៥._

ការអនុញ្ញាតឱ្យនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ មិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគរួចផុតពីការទទួលបាននូវការអនុញ្ញាត អាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬបញ្ជិកានានាដែលតម្រូវដោយស្ថាប័នមានសមត្ថកិច្ចតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៦._**

មន្ត្រីទទួលបន្ទុកត្រូវចាត់ចែងសំណុំពាក្យស្នើសុំការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ តាមនីតិវិធីរបស់ អ.គ.វ.វ.ខ. ដែលបានកំណត់ និងមិនត្រូវពន្យារពេលដោយគ្មានមូលហេតុច្បាស់លាស់។

មន្ត្រីទទួលបន្ទុក ដែលទទួលពាក្យស្នើសុំលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ត្រូវចេញលិខិតបញ្ជាក់អំពីការទទួលសំណុំពាក្យស្នើសុំនេះជូនអ្នកដាក់ពាក្យសុំ សម្រាប់ការមកទទួលយកលិខិតអនុញ្ញាតឱ្យនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ។

អ.គ.វ.វ.ខ. ត្រូវចាត់ចែងពិនិត្យ និងសម្រេចលើការស្នើសុំការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ តាមរយៈយន្តការអន្តរស្ថាប័នស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ យន្តការអន្តរស្ថាប័នរួមមាន ទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត, មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត, នាយកដ្ឋានគយ និងរដ្ឋាកររាជធានីភ្នំពេញ, សាខាគយ និងរដ្ឋាករខេត្ត, ទីចាត់ការពន្ធដាររាជធានី, សាខាពន្ធដារខេត្ត និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។ យន្តការអន្តរស្ថាប័នត្រូវផ្តល់មតិឯកភាព ឬបដិសេធនៅក្នុងអង្គប្រជុំ ឬជាលាយលក្ខណ៍អក្សរលើការស្នើសុំលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ដោយគ្មានការយឺតយ៉ាវ តាមគោលការណ៍ និងនីតិវិធីកំណត់។

អ.គ.វ.វ.ខ. ត្រូវផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋជូនអ្នកដាក់ពាក្យសុំ បន្ទាប់ពីទទួលបានការសម្រេចតាមរយៈយន្តការអន្តរស្ថាប័ន។

**ប្រការ៧._**

វិនិយោគិនមានកាតព្វកិច្ចផ្តល់របាយការណ៍អំពីប្រតិបត្តិការនាំចេញ-នាំចូលតាមទម្រង់កំណត់ដូចខាងក្រោម៖

១.វិនិយោគិនមានកាតព្វកិច្ចផ្តល់ជូន អ.គ.វ.វ.ខ. នូវរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ដូចខាងក្រោម៖

ក. ការនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និង/ឬធាតុចូលផលិតកម្មសម្រាប់បម្រើខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន។

ខ. ការនាំចេញនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម ធាតុចូលផលិតកម្ម និងផលិតផលសម្រេច។

គ. ការបំពេញកាតព្វកិច្ចសារពើពន្ធស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

ឃ. ការអនុវត្តគម្រោងវិនិយោគជាក់ស្តែង ដោយបញ្ជាក់ពីទុនវិនិយោគ ចំនួនបុគ្គលិក-កម្មករ ស្ថានភាពផលិតកម្ម ស្ថានភាពទីផ្សារ និងការអនុវត្តកាតព្វកិច្ចការពារបរិស្ថានសង្គម។

២.ទម្រង់នៃរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំខាងលើនេះ មានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៨._**

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំផ្ដល់ការបណ្ដុះបណ្ដាលដល់ អ.គ.វ.រ.ខ. និងអង្គភាពពាក់ព័ន្ធ ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តនីតិវិធីស្នើសុំផ្ដល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ។

**ប្រការ៩._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៦រោច ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មករា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- សាខាគយ និងរដ្ឋាករាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១

# ពាក្យស្នើសុំនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ

| |
|---|
| **ឈ្មោះក្រុមហ៊ុន (ជាភាសាខ្មែរ និងបរទេស)** |
| **អាសយដ្ឋាន** |

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត.......**

**និងជាប្រធានអនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត......**

**កម្មវត្ថុ** : សំណើសុំនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់គម្រោង..............

**យោង** :
- ព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត
- ប្រកាសអន្តរក្រសួងលេខ .......... ចុះថ្ងៃទី........ ខែ......... ឆ្នាំ... របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្តីពីនីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត
- វិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ............. ចុះថ្ងៃទី.......ខែ......ឆ្នាំ...... របស់អនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត.........

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ មានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តម/លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត.........មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថាបន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាតឱ្យវិនិយោគពីអនុគណៈកម្មាធិការវិនិយោគ.............លើគម្រោង................ដែលមានទីតាំងស្ថិតនៅភូមិ.........ឃុំ/សង្កាត់.........ស្រុក/ខណ្ឌ.........ខេត្ត/រាជធានី

.............. ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ សូមគោរពស្នើសុំនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម (ដូចមានក្នុង បញ្ជីមេទំនិញភ្ជាប់ជូន) សម្រាប់បម្រើដល់ការអនុវត្តគម្រោង..................នាពេលខាងមុខ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តម/លោកជំទាវ មេត្តាអនុញ្ញាតឱ្យក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ នាំចូលនូវមុខទំនិញទាំងនោះ ដោយក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។

សូម ឯកឧត្តម/លោកជំទាវ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ................ ខែ.......... ឆ្នាំ......... ព.ស.២៥៦...

រាជធានី/ខេត្ត......... ថ្ងៃទី.....ខែ.....ឆ្នាំ.........

**ប្រធានក្រុមហ៊ុន**

(ហត្ថលេខ ត្រា និងឈ្មោះ)

APPLICATION FOR CUSTOMS DUTY EXEMPTION

COMPANY : .................

PHONE No : .................

FILE No : .................

| ITEM No | DESCRIPTION OF GOODS | MODEL/COUNTRY | SERIAL No | NEW/ USED | UNIT | QUANTITY | UNIT PRICECE (USD) | TOTAL PRICE (USD) | REMARKS |
|---|---|---|---|---|---|---|---|---|---|
| **I- MACHINERY AND EQUIPMENT** | | | | | | | | | |
| 1 | | | | | | | | | |
| 2 | | | | | | | | | |
| TOTAL (I) | | | | | | | | | |
| **II- RAW MATERIALS AND ACCESSORIES** | | | | | | | | | |
| 1 | | | | | | | | | |
| 2 | | | | | | | | | |
| TOTAL (II) | | | | | | | | | |
| **III- CHEMICAL** | | | | | | | | | |
| 1 | | | | | | | | | |
| 2 | | | | | | | | | |
| TOTAL (III) | | | | | | | | | |
| **IV- OTHERS** | | | | | | | | | |
| 1 | | | | | | | | | |
| 2 | | | | | | | | | |
| TOTAL (IV) | | | | | | | | | |
| GRAND TOTAL (I+II+III+IV) | | | | | | | | | |

DATE OF SUBMISSION: ............./.........../……....

SIGNATURE AND STAMP

DIRECTOR

(NAME)

Any misrepresentation or omission of information by the investor may result in the cancellation of the incentive granted to investor

## ឧបសម្ព័ន្ធទី ២

# លិខិតអនុញ្ញាតឱ្យនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និង ធាតុចូលផលិតកម្ម ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| និមិត្តសញ្ញា<br>រដ្ឋបាលរាជធានី ខេត្ត |

**រដ្ឋបាលរាជធានី/ខេត្ត**
**អនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត**
លេខ...............................................

ថ្ងៃ..................ខែ.........ឆ្នាំ............. ព.ស.២៥៦.....
រាជធានី/ខេត្ត..... ថ្ងៃទី.........ខែ...........ឆ្នាំ២០.......

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា**

**កម្មវត្ថុ**: ករណីសំណើសុំនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់គម្រោង...........របស់ក្រុមហ៊ុន...................។

**យោង** :
- លិខិតស្នើសុំរបស់ក្រុមហ៊ុន ចុះថ្ងៃទី..........ខែ.........ឆ្នាំ.........ដែលអនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត.......... បានទទួលនៅថ្ងៃទី.......ខែ.......ឆ្នាំ...........
- ព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត
- ប្រកាសអន្តរក្រសួងលេខ .......... ចុះថ្ងៃទី........ ខែ.......... ឆ្នាំ... របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្តីពីនីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត
- វិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ.............. ចុះថ្ងៃទី......... ខែ......... ឆ្នាំ........... របស់អនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត..................
- ស្មារតីអង្គប្រជុំអន្តរស្ថាប័ន នាថ្ងៃទី.......ខែ........ឆ្នាំ............។

**ជូនភ្ជាប់**: បញ្ជីមេទំនិញស្នើសុំនាំចូលចំនួន ១ (មួយ)ច្បាប់។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា អនុគណៈកម្មាធិការវិនិយោគ.................បានសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន...........ដែលមានទីតាំងស្ថិតនៅភូមិ..........ឃុំ/សង្កាត់..........ស្រុក/ខណ្ឌ.........ខេត្ត/រាជធានី...................នាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់គម្រោង.......................... នាំចេញ/ផ្គត់ផ្គង់ឱ្យ គ.ល.គ. បម្រើឱ្យការនាំចេញ/បម្រើទីផ្សារក្នុងស្រុក តាមបរិមាណដូចខាងក្រោម៖

**I. MACHINERY AND EQUIPMENT**:

-ចំណុចលេខ.....ដល់លេខ.....តាមសំណើ

សរុបទឹកប្រាក់ស្មើនឹង .....USD (.....ដុល្លារអាមេរិក)

**II. RAW MATERIALS AND ACCESSORIES:**

-ចំណុចលេខ.....ដល់លេខ.....តាមសំណើ

សរុបទឹកប្រាក់ស្មើនឹង .....USD (.....ដុល្លារអាមេរិក)

**III. CHEMICALS:**

-ចំណុចលេខ.....ដល់លេខ.....តាមសំណើ

សរុបទឹកប្រាក់ស្មើនឹង.....USD (.....ដុល្លារអាមេរិក)

**IV. OTHERS:**

-ចំណុចលេខ.....ដល់លេខ.....តាមសំណើ

សរុបទឹកប្រាក់ស្មើនឹង .....USD (.....ដុល្លារអាមេរិក)

**កំណត់សម្គាល់៖**

១- ការអនុញ្ញាតឱ្យនាំចូល ដោយផ្ដល់ជូននូវការលើកទឹកចិត្តខាងលើនេះមានទិសដៅសំខាន់សម្រាប់បម្រើតម្រូវការគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ "គ.ល.គ." របស់ក្រុមហ៊ុនស្របតាមមុខសញ្ញាកំណត់។

២- ក្រោយពេលនាំចូល អ.គ.វ.រ.ខ. នឹងចាត់តាំងក្រុមត្រួតពិនិត្យចុះតាមដានការប្រើប្រាស់នូវរាល់ទំនិញដែលបាននាំចូលខាងលើនេះ ហើយរយៈពេល ៦ខែ ក្រោយការនាំចូលនឹងមានធ្វើការត្រួតពិនិត្យជា Post Audit ពីអន្តរស្ថាប័នមានសមត្ថកិច្ច។

៣- ករណីពិនិត្យឃើញថា ក្រុមហ៊ុនបានប្រើប្រាស់ការលើកទឹកចិត្តមិនចំមុខសញ្ញាវិនិយោគទេនោះ ក្រុមហ៊ុននឹងត្រូវទទួលរងការបង់ពន្ធ ការពិន័យ និងទោសទណ្ឌតាមច្បាប់ជាធរមាន។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ចម្លងជូន៖**

- *អគ្គនាយកដ្ឋានពន្ធដារ*
- *មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី ខេត្ត*
- *សាខាគយ និង រដ្ឋាករាជធានី ខេត្ត*
- *ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត*
- *ក្រុមហ៊ុន....................*
- *ឯកសារ-កាលប្បវត្តិ*

**អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត...**

**និងជាប្រធានអនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត...**

(ហត្ថលេខា និង ឈ្មោះ)

សេចក្ដីបញ្ជាក់៖ លិខិតអនុញ្ញាតនេះមានសុពលភាពប្រើប្រាស់ក្នុងរយៈពេល ១២ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

## ឧបសម្ព័ន្ធ ២.១

## កំណត់បង្ហាញអង្គប្រជុំអន្តរស្ថាប័ន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី/ខេត្ត**
**អនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត..................**

## កំណត់បង្ហាញ

**អង្គប្រជុំអន្តរស្ថាប័ន...............ថ្ងៃទី.......ខែ.......ឆ្នាំ..........**

**ប្រភពសំណើ** : ក្រុមហ៊ុន......................

**លិខិត** : ចុះថ្ងៃទី........ខែ.......ឆ្នាំ......... ដែល អ.គ.វ.រ.ខ. បានទទួលនៅថ្ងៃទី.......ខែ.......ឆ្នាំ........

**កម្មវត្ថុ** : ករណីសំណើសុំនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់គម្រោង.............របស់ក្រុមហ៊ុន...................។

**មតិជំនាញ**

ដូចមាននៅក្នុងសេចក្តីព្រាងជូនភ្ជាប់

**មតិសម្រេចរបស់អង្គប្រជុំ**

-MACHINERY AND EQUIPMENT:

-ចំណុចលេខ......ដល់លេខ......ឯកភាពផ្តល់ជូនតាមសំណើ។

-RAW MATERIAL AND ACCESSORIES:

-ចំណុចលេខ......ដល់លេខ......ឯកភាពផ្តល់ជូនតាមសំណើ។

-CHEMICAL:

-ចំណុចលេខ......ដល់លេខ......ឯកភាពផ្តល់ជូនតាមសំណើ។

-OTHERS:

-ចំណុចលេខ......ដល់លេខ......ឯកភាពផ្តល់ជូនតាមសំណើ។

**បានឃើញ និងឯកភាព**

ប្រធានអង្គប្រជុំ

## ឧបសម្ព័ន្ធ ២.២

## កំណត់បង្ហាញមតិរបស់មន្ត្រីជំនាញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី/ខេត្ត**
**អនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត**
**ទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាល**................

## កំណត់បង្ហាញ

**ប្រភពសំណើ** : ក្រុមហ៊ុន.......................

**លិខិត** : ចុះថ្ងៃទី........ខែ.......ឆ្នាំ......... ដែល អ.គ.វ.រ.ខ. បានទទួលនៅថ្ងៃទី.......ខែ.......ឆ្នាំ........

**កម្មវត្ថុ** : ករណីសំណើសុំនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់គម្រោង.............របស់ក្រុមហ៊ុន...................។

**យោង** : បញ្ជីមេទំនិញ/របាយការណ៍កាត់ស្តុកស្តីពីការនាំចេញ-នាំចូលប្រចាំត្រីមាសរបស់ក្រុមហ៊ុន។

## ខ្លឹមសារសង្ខេប

ក្រុមហ៊ុន......................... បានទទួលវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគពី អ.ន.វ.រ.ខ. តាមលិខិតលេខ................ ចុះថ្ងៃទី..........ខែ..........ឆ្នាំ..........លើគម្រោង.......................................ដែលមានទីតាំងស្ថិតនៅភូមិ.........ឃុំ/សង្កាត់........ស្រុក/ខណ្ឌ........ខេត្ត/រាជធានី......... ដែលមានទុនវិនិយោគសរុបចំនួន....................... ដុល្លារអាមេរិក។ ក្នុងនោះរួមមាន៖

- គ្រឿងម៉ាស៊ីន-សម្ភារៈបរិក្ខារ : .................. ដុល្លារអាមេរិក
- វត្ថុធាតុដើម : .................. ដុល្លារអាមេរិក

សូមគោរពជូនមតិ៖

..........................................................................................................................................

..........................................................................................................................................។

សូម ឯកឧត្តម/លោកជំទាវ ប្រធាន មេត្តាពិនិត្យសម្រេច និងសូមដាក់ករណីនេះ ជូនអង្គប្រជុំអន្តរស្ថាប័នពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់។

ដោយក្តីគោរព

ថ្ងៃ.............. ខែ......... ឆ្នាំ......... ព.ស.២៥៦...

រាជធានី/ខេត្ត.....ថ្ងៃទី........ខែ.........ឆ្នាំ២០.........

(ហត្ថលេខា និងឈ្មោះ)

# ឧបសម្ព័ន្ធទី ៣
## ទម្រង់នៃរបាយការណ៍អំពីប្រតិបត្តិការនាំចេញ-នាំចូល

ក្រុមហ៊ុន : ..................

អាសយដ្ឋាន : ..................

ទូរសព្ទ : ..................

## តារាងរបាយការណ៍នាំចូល
## នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម

តាមលិខិតលេខ....ចុះថ្ងៃទី...ខែ...ឆ្នាំ... របស់អនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត....

ចាប់ពីថ្ងៃទី.... ខែ.... ឆ្នាំ.... ដល់ថ្ងៃទី.... ខែ.... ឆ្នាំ....

| ITEM No | DESCRIPTION OF GOODS | ឯកតា | បានអនុញ្ញាតពី អ.គ.វ.ខ. | | | ឆមាសទី១ | | ឆមាសទី២ | | នៅសល់ចុងក្រោយ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | តម្លៃរាយ | តម្លៃសរុប | បរិមាណ | ទឹកប្រាក់ | បរិមាណ | ទឹកប្រាក់ | បរិមាណ | ទឹកប្រាក់ |
| **I- MACHINERY AND EQUIPMENT** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| TOTAL (I) | | | | | | | | | | | |
| **II- RAW MATERIALS AND ACCESSORIES** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| TOTAL (II) | | | | | | | | | | | |
| **III- CHEMICAL** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| TOTAL (III) | | | | | | | | | | | |
| **IV- OTHERS** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| TOTAL (IV) | | | | | | | | | | | |
| GRAND TOTAL (I+II+III+IV) | | | | | | | | | | | |

DATE: ............../............/20...........

SIGNATURE AND STAMP

DIRECTOR

ក្រុមហ៊ុន : ..................

អាសយដ្ឋាន : .................

ទូរសព្ទ : ..................

# តារាងរបាយការណ៍នាំចេញ

ចាប់ពីថ្ងៃទី.... ខែ.... ឆ្នាំ.... ដល់ថ្ងៃទី.... ខែ.... ឆ្នាំ....

| No | ប្រតិវេទន៍គយ | | Invoice No. | | ឈ្មោះទំនិញនិងយថាប្រភេទ | បរិមាណ | តម្លៃរាយ | តម្លៃសរុប | ទម្ងន់សុទ្ធ | ទម្ងន់សរុប | គោលដៅ |
|---|---|---|---|---|---|---|---|---|---|---|---|
| | លេខ | កាលបរិច្ឆេទ | លេខ | កាលបរិច្ឆេទ | | PCS | USD | USD | N.W | G.W | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| 3 | | | | | | | | | | | |
| 4 | | | | | | | | | | | |
| សរុបឆមាសទី ១ | | | | | | | | | | | |
| 5 | | | | | | | | | | | |
| 6 | | | | | | | | | | | |
| 7 | | | | | | | | | | | |
| សរុបឆមាសទី ២ | | | | | | | | | | | |
| | | | | | | | | | | | |
| សរុបប្រចាំឆ្នាំ | | | | | | | | | | | |

DATE: ............../............/20...........

SIGNATURE AND STAMP

DIRECTOR